**ការកំទេចពូជសាសន៍** (Ethnic Cleansing: EC)

EC សំដៅគោលនយោបាយ ឬការអនុវត្តជាច្រើន ក្នុងគោលបំណងដកចេញ (displace) ក្រុមជាតិពន្ធុ ពីដែនដីជាក់លាក់ណាមួយ។ ការដកចេញ ត្រូវបានបន្តដោយសកម្មភាពលុបបំបាត់ដាននូវរូបវន្ត ដូចជាការបំផ្លាញ វត្ថុឬទីតាំងវប្បធម៌ សាសនា និងកំណត់ត្រារូបវន្ត។

ទង្វើដកចេញដោយពួកក្រហម នូវក្រុមជាតិពន្ធុផ្សេងទៀត ជាឧទាហរណ៍ នៃការជម្រះពូជសាសន៍។ EC ជាទង្វើដេញចេញដោយបង្ខំ (forced deportation) ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងក្នុងមាត្រា៧ នៃលក្ខន្តិកៈស្តីពី ICC។

មហាសន្និបាតអង្គការសហប្រជាជាតិ ធ្លាប់ថ្កោលទោសទង្វើនេះ ក្នុងសេចក្តីសម្រេច Res. 47/80 ចុះថ្ងៃទី ១៦ ខែធ្នូឆ្នាំ ១៩៩២ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p.312)។

**ខ្លឹមសារបន្ថែម៖** EC ខុសពីអំពើប្រល័យពូជសាសន៍ ដោយសារ មិនតម្រូវនូវចេតនាពិសេស បំផ្លាញពូជសាសន៍ និងខុសពីការសម្លាប់រង្គាល (extermination/mass killing) ដោយសារ ការសម្លាប់រង្គាល មិនផ្តោតលើពូជសាសន៍ណាមួយ។